# ព័ត៌មានទូទៅសម្រាប់ SUN Bucks ឆ្នាំ 2026

## តើកម្មវិធី SUN Bucks ជាអ្វី?



កម្មវិធី SUN Bucks ផ្តល់ជូនគ្រួសារនូវប្រាក់ $120 សម្រាប់កុមារម្នាក់ៗដែលមានសិទ្ធិ ដើម្បីទិញអាហារនៅរដូវក្តៅពេលសាលាបិទទ្វារ។ កាត SUN Bucks ត្រូវបានទទួលយកនៅទីតាំងដែលកាត CalFresh EBT ត្រូវបានទទួលយក។ **ការទទួលបាន SUN Bucks មិនប៉ះពាល់ដល់ស្ថានភាពអន្តោប្រវេសន៍របស់គ្រួសារអ្នកទេ។**

## ការចុះឈ្មោះដោយស្វ័យប្រវត្តិសម្រាប់ SUN Bucks 2026

កុមារដែលមានអាយុចន្លោះពី 6 ដល់ 18 ឆ្នាំ ដែលទទួលបាន CalFresh, CalWORKs និង/ឬ Medi-Cal ហើយមានប្រាក់ចំណូលស្មើ ឬទាបជាង 185% នៃកម្រិតភាពក្រីក្រសហព័ន្ធ (FPL) នឹងទទួលបាន SUN Bucks ដោយស្វ័យប្រវត្តិ។ សិស្សដែលមានសិទ្ធិទទួលអាហារពេលបាយសាលាឥតគិតថ្លៃ ឬតម្លៃបន្ថយដោយផ្អែកលើការចូលរួមទទួលអត្ថប្រយោជន៍សាធារណៈ ឬស្ថានភាពជាក្មេងជំទង់ចំណាកស្រុក គ្មានផ្ទះសម្បែង ឬកុមារក្រោមការថែទាំរបស់រដ្ឋ នឹងទទួលបាន SUN Bucks ដោយស្វ័យប្រវត្តិផងដែរ។



## ធ្វើដូចម្តេចដើម្បីទទួលបាន SUN Bucks?



ប្រសិនបើកូនរបស់អ្នកមិនត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិចូលរួមកម្មវិធី SUN Bucks ទេ អ្នកត្រូវតែដាក់ពាក្យស្នើសុំទៅសាលា ឬស្រុកសាលារបស់កូនអ្នក **ត្រឹមពីថ្ងៃទី 31 ខែសីហា ឆ្នាំ 2026** ដើម្បីពិនិត្យមើលថាអ្នកមានសិទ្ធិឬអត់។

សិស្សដែលមិនទទួលជំនួយសាធារណៈ និងមិនត្រូវបានសាលារបស់ពួកគេកំណត់ថាជាសិស្សចំណាកស្រុក សិស្សគ្មានផ្ទះ ឬសិស្សដែលស្ថិតនៅក្រោមការថែទាំ**ត្រូវតែ**ដាក់ពាក្យដើម្បីឲ្យកំណត់សិទ្ធិមានលក្ខណៈសម្បត្តិរបស់ពួកគេសម្រាប់ SUN Bucks។ ការទទួលបានអាហារនៅសាលាដោយឥតគិតថ្លៃ **មិន**ធានាការចុះឈ្មោះ SUN Bucks ទេ។

កុមារដែលទទួលបាន Medi-Cal នឹងទទួលបាន SUN Bucks ដោយស្វ័យប្រវត្តិ ប្រសិនបើចំណូលរបស់គ្រួសារពួកគេនៅ ឬក្រោម 185% នៃ FPL។ ឧទាហរណ៍ កុមារដែលទទួលបាន Medi-Cal និង ប្រាក់ជំនួយសន្តិសុខបន្ថែម (SSI/SSP), ប្រាក់ជំនួយទទួលអនុម័តអាណាព្យាបាល (AAP), ប្រាក់ជំនួយអាណាព្យាបាលជំនាន់ក្រោយ (KIN GAP) ឬប្រាក់ជំនួយសាច់ប្រាក់ ឬ ការថែទាំកុមារជំនួស (FC) ត្រូវតែដាក់ពាក្យព្រោះ Medi-Cal របស់គ្រួសារទាំងនេះមិនត្រូវបានបញ្ជាក់ថា ស្ថិតនៅកម្រិត 185% ឬក្រោមនៃ FPL ទេ។ បើអ្នកមិនប្រាកដទេ សូមដាក់ពាក្យ។

## ការរំលឹករាក់ទាក់៖

- **តើអ្នកបានផ្លាស់ទីនៅពេលថ្មីៗនេះទេ? ធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងរបស់អ្នក** ជាមួយការិយាល័យអ្នកគ្រប់គ្រងសាលា ឬសាលារបស់កូនអ្នក ការិយាល័យសេវាសង្គមក្នុងមូលដ្ឋាន របស់អ្នក ឬនៅ BenefitsCal.com។
- **រាយការណ៍អំពីបញ្ហាកាត SUN Bucks ទៅកាន់បណ្តាញជំនួយ SUN Bucks តាមរយៈ (877) 328-9677។** គ្រួសារមួយមិនអាចទទួលបានកាត SUN Bucks ច្រើនជាងមួយក្នុងកូនម្នាក់ៗ ឬទទួលបាន SUN Bucks ពីរដ្ឋច្រើនជាងមួយ។
- **SUN Bucks ផុតកំណត់ 122 ថ្ងៃបន្ទាប់ពីត្រូវបានផ្ទុកនៅលើកាត។** គ្រួសារត្រូវបានលើកទឹកចិត្តឱ្យចំណាយ SUN Bucks របស់ពួកគេ មុនពេលអត្ថប្រយោជន៍ CalFresh ។ សូមពិនិត្យមើលព័ត៌មានលម្អិតអំពីសមតុល្យរបស់អ្នកនៅ www.ebtedge.com។

## ចង់ស្វែងយល់បន្ថែម?

- ចូលមើល www.cdss.ca.gov/sun-bucks ឬស្កេនកូដ QR។

**ស្ថាប័ននេះគឺជាអ្នកផ្តល់ឱកាសស្មើគ្នា។ SUN Bucks ទទួលបានមូលនិធិពីក្រសួងកសិកម្ម ស្បៀងអាហារ និងអាហារូបត្ថម្ភសហរដ្ឋអាមេរិក។**
**2026 | សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ www.fns.usda.gov/summer។**
**www.cde.ca.gov/ls/nu/sf | SUNBucks@dss.ca.gov**